**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
******

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលលោកជំទាវ Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នៅព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**លោកជំទាវ** Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលានៅទីស្តីការក្រសួង ក្នុងឱកាសដែលលោកជំទាវឯកអគ្គរដ្ឋទូតចប់អាណត្តិបេសកកម្មការទូតនៅកម្ពុជា។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់លោកជំទាវដែលបានរួមចំណែកយ៉ាងសំខាន់ធ្វើឱ្យទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងអូស្ត្រាលី កាន់តែទូលំទូលាយ និងស៊ីជម្រៅបន្ថែមទៀត ជាពិសេស ការផ្តួចផ្តើមបង្កើតយន្តការកិច្ចពិភាក្សាថ្នាក់ឧត្តមមន្ត្រីក្រសួងការបរទេសនៃប្រទេសទាំងពីរ ដែលបានធ្វើកិច្ចប្រជុំលើកទីមួយប្រកបដោយផ្លែផ្កា នៅរដ្ឋធានីកង់បេរ៉ា ប្រទេសអូស្ត្រាលី កាលពីខែកញ្ញា ឆ្នាំ២០១៩។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ពីការត្រៀមផ្តល់កិច្ចសហការ និងជួយគាំទ្រឯកអគ្គរដ្ឋទូតថ្មីរបស់អូស្ត្រាលីក្នុងបេសកកម្មការទូតនៅកម្ពុជា និងបន្តលើកកម្ពស់ទំនាក់ទំនងមិត្តភាពរវាងកម្ពុជា និងអូស្ត្រាលី។

ជាការឆ្លើយតប **លោកជំទាវឯកអគ្គរដ្ឋទូត** បានសំដែងក្តីរីករាយនិងពេញចិត្តដោយទទួលបានកិច្ចសហការយ៉ាងល្អពីគ្រប់ក្រសួង-ស្ថាប័នកម្ពុជា ជាពិសេសក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានជួយឲ្យលោកជំទាវបំពេញបេសកកម្មការទូតនៅកម្ពុជា ទទួលបានជោគជ័យ។ **លោកជំទាវ** បានលើកអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរលើវិស័យសន្តិសុខ មានជាអាទិ៍ ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងអំពើភេរវកម្ម និងលើវិស័យជាច្រើនទៀតរួមមាន កសិកម្ម សុខាភិបាល ការដោះមីន ហេដ្ឋារចនាសម្ព័ន្ធ និងអប់រំ ដែលក្នុងអាណត្តិរបស់លោកជំទាវមាននិស្សិតកម្ពុជាចំនួន១៧៨រូប បានទទួលអាហារូបករណ៍ទៅសិក្សានៅអូស្ត្រាលី។

**លោកជំទាវឯកអគ្គរដ្ឋទូត** ក៏បានបញ្ជាក់ថា ក្នុងនាមប្រទេសជាមិត្តជាយូរមកហើយ អូស្ត្រាលីនឹងបន្តជួយគាំទ្រដល់ការអភិវឌ្ឍកម្ពុជា ហើយរីករាយនឹងផ្តួចផ្តើមអោយមានការផ្លាស់ប្តូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំវ័យក្មេងរវាងប្រទេសទាំងពីរផងដែរ។ ក្រៅពីនេះ លោកជំទាវ បានកោតសរសើរពលរដ្ឋខ្មែរកំពុងរស់នៅក្នុងប្រទេសអូស្ត្រាលី ចំនួនប្រមាណ៦ម៉ឺននាក់ ដែលបានរួមចំណែកយ៉ាងសកម្មដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់អូស្ត្រាលី។ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ អាស៊ាន-អូស្ត្រាលី លោកជំទាវ

ចង់ឃើញកិច្ចប្រជុំកំពូលអាស៊ាន-អូស្ត្រាលី ប្រារព្ធធ្វើឡើងជាទៀងទាត់ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការកាន់តែស៊ីជំរៅថែមទៀត។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលី ដែលបានជួយរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា តាមរយៈការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ដែលគិតចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០១៨ មានចំនួនប្រមាណ**មួយពាន់លាន**ដុល្លារសហរដ្ឋអាមេរិក។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានសំដែងក្តីរីករាយ ដែលរដ្ឋាភិបាលអូស្ត្រាលីនៅបន្តជួយផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងការបណ្តុះបណ្តាលជំនាញ តាមរយៈការផ្តល់អាហារូបករណ៍ និងវគ្គសិក្សានានា ដោយបង្កើនវគ្គរយៈពេលខ្លី និងរក្សាចំនួនវគ្គរយៈពេលវែង ដល់និស្សិតកម្ពុជា។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង**លោកជំទាវឯកអគ្គរដ្ឋទូត** បានពិភាក្សាអំពីមធ្យោបាយក្នុងការជំរុញទំនាក់ទំនងពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ រវាងកម្ពុជា-អូស្ត្រាលីបន្ថែមទៀត ឲ្យស្របតាមសក្តានុពលនៃប្រទេសទាំងពីរ ខណៈដែលទំហំពាណិជ្ជកម្មទំនិញទ្វេភាគីមានចំនួនប្រមាណ១៦០លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។

ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈគ្នាផងដែរ លើបញ្ហាតំបន់និងអន្តរជាតិមួយចំនួន ដែលជាកង្វល់និងការចាប់អារម្មណ៍រួម៕